# ការចូលរួមក្នុងការណាត់ជួបរបស់អ្នក តាមរយៈការហៅតាមវីដេអូ

Monash Health

**នៅពេលណាសមស្រប អ្នកអាចមានការពិគ្រោះយោបល់តាមអនឡាញ តាមរយៈការហៅតាមវីដេអូ**

ការហៅតាមវីដេអូមានភាពងាយស្រួលដូចការហៅតាមទូរសព្ទដែរ ដោយមានការជួបទល់មុខផ្ទាល់ ដែលជាគុណភាពក្នុងការទាក់ទងគ្នា។

វាអាចសន្សំពេលវេលា និងប្រាក់ និងនាំការថែទាំរបស់អ្នកឱ្យកាន់តែជិតផ្ទះ។



## តើខ្ញុំត្រូវទៅកន្លែងណាដើម្បីចូលរួមក្នុងការណាត់ជួប?

**ដើម្បីចូលរួមក្នុងការណាត់ជួប សូមចូលទៅកាន់៖**

www.monashhealth.org/services/telehealth

**ឬប្រើប្រាស់លេខកូដ QR នេះ ដើម្បីចូលទៅក្នុងកន្លែងរង់ចាំរបស់គ្លីនិក៖**

ជាជាងធ្វើដំណើរទៅកាន់ការណាត់ជួបរបស់អ្នក អ្នកចូលតាមអនឡាញទៅក្នុងកន្លែងរង់ចាំរបស់គ្លីនិក។ សេវាកម្មសុខភាពនឹងត្រូវបានជូនដំណឹងនៅពេលអ្នកចូលមកដល់ ហើយគ្រូពេទ្យគ្លីនិករបស់អ្នកនឹងចូលរួមជាមួយអ្នកនៅពេលរួចរាល់ហើយ។ មិនត្រូវការបង្កើតគណនីទេ។ គ្មានព័ត៌មានដែលអ្នកបញ្ចូលត្រូវបានរក្សាទុកទេ។

## តើខ្ញុំត្រូវការអ្វីខ្លះដើម្បីធ្វើការហៅតាមវីដេអូ?

- **ការភ្ជាប់អ៊ីនធឺណិតល្អមួយ**
  ប្រសិនបើអ្នកអាចមើលវីដេអូតាមអនឡាញ (ឧទាហរណ៍ YouTube) នោះអ្នកអាចធ្វើការហៅតាមវីដេអូបាន
- **មានទីកន្លែងមួយដែលមានលក្ខណៈឯកជន មានពន្លឺល្អ ដែលអ្នកមិនត្រូវបានគេរំខាន** នៅក្នុងអំឡុងនៃការពិគ្រោះយោបល់
- **ជាទម្រង់ថ្មីៗមួយនៃកម្មវិធីរុករកវិប (Web Browsers) ទាំងនេះដូចដែលបានបង្ហាញនៅលើទំព័រម្ខាងទៀត៖**
  - Google Chrome, Microsoft Edge, Mozilla Firefox ឬ Apple Safari
- **កាមេរ៉ាវិប (Web-camera), ឧបករណ៍បំពងសំឡេង (speakers) និងមីក្រូហ្វូន (microphone)**
  (បានដំឡើងរួចហើយនៅក្នុងកុំព្យូទ័រយួរដៃ ឬឧបករណ៍ចល័ត)

សូមមើលទៅម្ខាងទៀតសម្រាប់ព័ត៌មានបន្ថែមស្ដីពីរបៀបដើម្បីធ្វើការហៅតាមវីដេអូ។

## តើវាមានសុវត្ថិភាពឬទេ?

ការហៅតាមវីដេអូមានសុវត្ថិភាព ហើយឯកជនភាពរបស់អ្នកត្រូវបានការពារ។ អ្នកមានបន្ទប់វីដេអូឯកជនផ្ទាល់ខ្លួន ដែលមានតែគ្រូពេទ្យគ្លីនិកដែលមានសិទ្ធិអនុញ្ញាតតែប៉ុណ្ណោះទើបអាចចូលបាន។

## តើការហៅតាមវីដេអូត្រូវចំណាយថ្លៃប៉ុន្មានដែរ?

ការហៅតាមវីដេអូគឺឥតគិតថ្លៃ (លើកលែងតែសម្រាប់ការប្រើប្រាស់អ៊ីនធឺណិតរបស់អ្នក)។ ទោះបីយ៉ាងណាក៏ដោយ ការចំណាយជាប្រចាំនៃការពិគ្រោះយោបល់ផ្នែកវេជ្ជសាស្ត្រនឹងកើតមាន។

## តើទិន្នន័យអ៊ីនធឺណិតចំនួនប៉ុន្មាននឹងត្រូវប្រើ?

អ្នកមិនប្រើប្រាស់ទិន្នន័យណាមួយ ខណៈពេលរង់ចាំ គ្រូពេទ្យគ្លីនិកដើម្បីចូលរួមជាមួយអ្នកទេ។

ការពិគ្រោះយោបល់តាមវីដេអូ ប្រើប្រាស់ទិន្នន័យតែពាក់កណ្ដាលនៃទិន្នន័យ(data) ដែលអ្នកប្រើសម្រាប់មើលវីដេអូ YouTube នៅក្នុងកម្រិតរូបភាពខ្ពស់ (High Definition) *។

ការប្រើទិន្នន័យ គឺអស់តិចសម្រាប់ការតភ្ជាប់អ៊ីនធឺណិតដែលមានល្បឿនទាប ឬប្រសិនបើអ្នកកំពុងប្រើកុំព្យូទ័រ ថេប្លិត ឬស្មាតហ្វូនដែលមានកំលាំងខ្សោយ។ កត្តាទាំងនេះក៏អាចកាត់បន្ថយគុណភាពរួមនៃការហៅផងដែរ។

ការប្រើប្រាស់ទិន្នន័យកើនឡើងនៅពេលមានអ្នកចូលរួមច្រើនជាងពីរនាក់នៅក្នុងការហៅវីដេអូ។

**អ្នកប្រើប្រាស់ទូរសព្ទស្មាតហ្វូន និងថេប្លិត**

ប្រសិនបើអ្នកអាច សូមភ្ជាប់ទៅបណ្ដាញ Wi-Fi នៅផ្ទះ ឬនៅកន្លែងធ្វើការដើម្បីជៀសវាងការប្រើទិន្នន័យនៃទូរសព្ទដែរបស់អ្នក។

* *នោះប្រហែលជាអស់ទិន្នន័យ 230 MB នៅលើឧបករណ៍ចល័ត និង 450 MB នៅលើ PC សម្រាប់រយៈពេលហៅ 20 នាទី ដែលស្រដៀងនឹង Skype® ឬ FaceTime® ដែរ។*

# ត្រៀមខ្លួនរួចជាស្រេចដើម្បីធ្វើការហៅតាមវីដេអូ



សូមធ្វើឱ្យប្រាកដថាអ្នកប្រើប្រាស់ទំរង់ថ្មីនៃកម្មវិធីរុករកតាមអ៊ីនធឺណិតមួយក្នុងចំណោមទំរង់ខាងក្រោមនេះ៖

- Google Chrome (Windows, Android, MacOS, iOS 14.3+)
- Apple Safari (MacOS, iOS)
- Mozilla Firefox (Windows, Android, MacOS, iOS 14.3+)
- Microsoft Edge (Windows, Android, MacOS, iOS 14.3+)

ចូលទៅកាន់ www.monashhealth.org/services/telehealth

1. ចុចប៊ូតុងចាប់ផ្តើមនៃការហៅតាមវីដេអូនៅក្នុងតំណដែលបានផ្តល់ឱ្យ ឬនៅលើគេហទំព័ររបស់សេវាកម្មសុខភាព។




2. បញ្ចូលឈ្មោះនិងព័ត៌មានលម្អិតនៅពេលមានការណែនាំចេញជាបន្តបន្ទាប់




3. សូមចូល ទៅក្នុងទីកន្លែងរង់ចាំតាមអនឡាញរបស់គ្លីនិក




4. គ្រូពេទ្យគ្លីនិកមកដល់ ហើយការពិគ្រោះយោបល់ចាប់ផ្តើមដំណើរការ



## តើខ្ញុំត្រូវធ្វើអ្វីខ្លះ ប្រសិនបើអ្វីមួយមិនដំណើរការ?

- ចូលទៅកាន់ https://vcc.healthdirect.org.au/troubleshooting

### ព័ត៌មានបន្ថែម

Telehealth Support Contact
Tel: +61 3 8572 3823
Email : telehealth@monashhealth.org

healthdirect Video Call